ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. ១៤០ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការទប់ស្កាត់សកម្មភាពផ្លាកផ្លូវ ដែលប៉ះពាល់ដល់ព្រះពុទ្ធសាសនា

## ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតម្រូវការចាំបាច់ក្នុងការជួយថែរក្សា និង លើកកំពស់កិត្យានុភាពព្រះពុទ្ធសាសនា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## សម្រេច

**ប្រការ១:** មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា ព្រះពុទ្ធសាសនាជាសាសនា របស់រដ្ឋ។ មាត្រា ៤(ខ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិន ស្មោះត្រង់ ចែងថា ម៉ាកដែលពុំអាចចុះបញ្ជីបានគឺ ម៉ាកទាំងឡាយណាដែលប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ។ ដូច្នេះរាល់សកម្មទាំងឡាយ រួមទាំងសកម្មភាព ផ្នែកពាណិជ្ជកម្ម ផលិតកម្ម

សេវាកម្ម និង សកម្មភាព សាធារណៈដទៃទៀត ដូចជាការសំដែងសិល្បៈរបាំ ប្រគុំដូរ្យតន្ត្រី ។ល។ ដែលធ្វើអោយ ប៉ះពាល់ ដល់ការគោរព បូជាចំពោះព្រះពុទ្ធសាសនា ត្រូវបានចាត់ទុកថា ជាសកម្មមាក់ងាយ ដល់ព្រះពុទ្ធសាសនា និង ប៉ះពាល់ដល់ប្រពៃណីជាតិ ។

**ប្រការ២:** ដោយយោងតាមខ្លឹមសារនៃប្រការ ១ ខាងលើ រាល់ការនាំចូល ការផលិត ការតាំងលក់ និង ការផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយផ្សេងៗ នូវផលិតផលជាសំភារៈប្រើប្រាស់ ផលិតផលតាំងលំអ រូបភាពឃោសនា ភេសជ្ជៈ គ្រឿងស្រវឹង ដែលប្រើរូបភាព និង រូបលំនាំ (Caricature) រូបថ្លុកពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ជាពិសេសការនាំចូល ការផលិត ការតាំងលក់ ខោខ្លីសំរាប់មុជទឹករបស់នារី ទៀនសំរាប់អុជក្នុងករណីផ្សេងក្រៅពីការបូជាព្រះពុទ្ធសាសនា ស្រាបៀរ សុរា ដែលមានបោះពុម្ព រូបភាពព្រះពុទ្ធនៅពីលើ និង ថាសចំរៀងដែលមាន ឈ្មោះថា " **Buddha Bar** " ត្រូវបានហាមឃាត់ជាដាច់ខាត ។

**ប្រការ៣:** ទង្វើទាំងឡាយណារបស់ អាជីវករ ផលិតករ សេវាករ ដែលផ្ទុយទៅនឹងការណែនាំក្នុង ប្រការ ២ខាងលើ ត្រូវចាត់ទុកជាអំពើល្មើស ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និង បទប្បញ្ញត្តិ ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** នាយកដ្ឋានកាំកុងត្រូល និងនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវសហការណ៍ជាមួយស្ថាប័នមានសមត្ថកិច្ច ដែលពាក់ព័ន្ធផ្សេងៗទៀត រាំងខ្ទប់នូវអំពើល្មើសទាំងឡាយ ដូចមានចែងក្នុងប្រការ២ នៅតាមមាត់ច្រកព្រំដែន និងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា អោយ ទទួលបានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៥:** ប្រកាសនេះចូលជាធរមាន ចាប់ពីពេលចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចំលងជូន**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខេង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ក្រសួងធម្មការ និង កិច្ចការសាសនា
- ទីចាត់ការគយ និង រដ្ឋាករ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ